# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា
## សាលា JOHN H. TAGGART
## ច្បាប់ស្តីពីការចូលរួមរបស់មាតាបិតា
## ២០១៥-២០១៦

## ផ្នែកទី I    ចំណងទូទៅ

សាលានីមួយៗ នៅក្នុងច្បាប់ស្តីពីការចូលរួមរបស់មាតាបិតា ទូទាំងសាលា ត្រូវបង្កើតនូវគោលបំណងរបស់សាលា សម្រាប់ការចូលរួមរបស់មាតាបិតា។ *[Section 1118(a)(2), ESEA.]*

សាលា John H. Taggart យល់ព្រមអនុវត្តនូវលក្ខន្តិកៈតាមការតម្រូវ ដូចតទៅនេះ៖

- ក្រសួងអប់រំនឹងចាប់ផ្តើមប្រតិបត្តិនូវ កម្មវិធី សកម្មភាព និងនីតិវិធី ផ្សេងៗ សម្រាប់ការចូលរួមរបស់មាតាបិតា នៅសាលាទាំងអស់របស់ក្រសួងអប់រំ តាមកម្មវិធី Title I, Part A ដែលស្របតាម មាត្រា លេខ១១១៨ នៃច្បាប់អប់រំ សាលាបឋមសិក្សា និង វិទ្យាល័យ (Elementary and Secondary Education Act, ESEA) ។ កម្មវិធី សកម្មភាព និងនីតិវិធី ទាំងនោះ ត្រូវរៀបចំ និងធ្វើឡើងតាមការប្រឹក្សាដ៏មានន័យជាមួយ មាតាបិតា របស់ក្មេងដែលចូលរួម។
- ឲ្យស្របតាមមាត្រាលេខ១១១៨ ក្រសួងអប់រំនឹងសហការជាមួយសាលាទាំងអស់របស់ក្រសួង ដើម្បីធ្វើយ៉ាងណាឲ្យច្បាប់ចូលរួមរបស់មាតាបិតា មានតាមកម្រិតសាលាដែលបានតម្រូវ ត្រូវតាមការតម្រូវរបស់មាត្រាលេខ១១១៨(b) នៃច្បាប់ ESEA ហើយច្បាប់នីមួយៗ មាន សមាសភាគកិច្ចសន្យា រវាងមាតាបិតា និងសាលា ដែលស្របតាមមាត្រាលេខ១១១៨(d) នៃច្បាប់ ESEA។
- ក្រសួងអប់រំនឹងបញ្ចូលច្បាប់ចូលរួមរបស់មាតាបិតាទូទាំងក្រសួងនេះ ទៅក្នុងគម្រោងការរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា ដែលបានអភិវឌ្ឍក្រោមមាត្រាលេខ១១១២ នៃច្បាប់ ESEA។
- ក្នុងការអនុវត្តន៍ច្បាប់ Title I, Part A ការតម្រូវនៃការចូលរួមរបស់មាតាបិតា តាមតែអាចធ្វើទៅបាន ក្រសួងអប់រំ និងសាលាទាំងអស់ នឹងផ្តល់ឱកាសចូលរួមយ៉ាងពេញទំហឹងដល់មាតាបិតា ដែលចេះភាសាអង់គ្លេសតិចតួច មាតាបិតាដែលពិការ និង មាតាបិតារបស់ក្មេងអន្តោប្រវេសន៍ រួមទាំងការផ្តល់ព័ត៌មាន និងរបាយការណ៍សាលា ដែលបានតម្រូវដោយមាត្រាលេខ១១១១ នៃច្បាប់ ESEA តាមរបៀបដែលអាចយល់ និងឯកសណ្ឋាន ហើយរួមទាំងទម្រង់ដែលអាចជំនួសបានតាមការស្នើសុំ និងតាមតែអាចធ្វើទៅបាន តាមភាសាដែល មាតាបិតាអាចយល់បាន។
- បើសិនជាគម្រោងការរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា សម្រាប់ Title I, Part A បានអភិវឌ្ឍក្រោមមាត្រាលេខ១១១២ នៃច្បាប់ ESEA មិនផ្តល់ការពេញចិត្តដល់មាតាបិតារបស់ក្មេងដែលចូលរួម ក្រសួងអប់រំនឹងផ្តល់យោបល់របស់មាតាបិតាជាមួយនឹងគម្រោងការនោះ នៅពេលក្រសួងអប់រំផ្តល់គម្រោងការទៅឲ្យ ក្រសួងអប់រំរដ្ឋ។
- ក្រសួងអប់រំនឹងនាំឲ្យមានការចូលរួមពីមាតាបិតារបស់ក្មេងនៅសាលា Title I, Part A ក្នុងការសម្រេចនូវការចំណាយប្រាក់ជំនួយ Title I, Part A ១ភាគរយ ត្រូវចំណាយដោយរបៀបណាសម្រាប់ការចូលរួមរបស់មាតាបិតា ហើយនឹងធ្វើយ៉ាងណាមិនឲ្យតិចជាង៩៥ភាគរយ នៃប្រាក់ជំនួយ ១ភាគរយនេះចំណាយទៅលើសាលា។
- ក្រសួងអប់រំនឹងត្រូវគ្រប់គ្រងដោយនិយមន័យនៃលក្ខន្តិកៈដូចតទៅ អំពីការចូលរួមរបស់មាតាបិតា ហើយសង្ឃឹមថា សាលាទាំងអស់ដែលនៅក្រោមច្បាប់ Title I នឹងមាន កម្មវិធី សកម្មភាព និងវិធី ផ្សេងៗដែលស្របតាមនិយមន័យនេះ៖

*ការចូលរួមរបស់មាតាបិតា មានន័យថា ជាការចូលរួមរបស់មាតាបិតាជាធម្មតា ទៅវិញទៅមក និងទំនាក់ទំនងដែលមានន័យ ទាក់ទងដល់ការសិក្សារបស់សិស្សានុសិស្ស និងសកម្មភាពសាលាផ្សេងៗទៀត រួមទាំងការបញ្ជាក់ថា—*

*(ក) មាតាបិតា មានមុខងារដ៏សំខាន់ ក្នុងការជួយដល់ការសិក្សារបស់កូន*

*(ខ) មាតាបិតា ត្រូវទទួលការលើកទឹកចិត្តឲ្យចូលរួមដោយសកម្មក្នុងការសិក្សារបស់កូននៅសាលា*

*(គ) មាតាបិតា ជាដៃគូយ៉ាងពេញទំហឹងក្នុងការសិក្សារបស់កូន និងតាមការសមរម្យ រួមទាំង ការសម្រេចចិត្ត និងជាក្រុមប្រឹក្សា ដើម្បីជួយដល់ការសិក្សារបស់កូន*

*(ឃ) ធ្វើសកម្មភាពផ្សេងៗ ដូចជាអ្វីៗដែលបានរៀបរាប់ក្នុងមាត្រា១១១៨ នៃច្បាប់ ESEA។*

- ក្រសួងអប់រំនឹងជូនដំណឹងដល់មាតាបិតា និងអង្គការមាតាបិតា អំពីគោលបំណង និងការមាន ព័ត៌មានសម្រាប់មាតាបិតា និង មណ្ឌលផ្តល់ព័ត៌មាន នៅក្នុងរដ្ឋ។

## ផ្នែកទី II ការរៀបរាប់អំពីវិធីដែលក្រសួងអប់រំនឹងបង្កើតច្បាប់ចូលរួមរបស់មាតាបិតាទូទាំងក្រសួងតាមការតម្រូវ

[កំណត់សម្គាល់៖ ច្បាប់ចូលរួមរបស់មាតាបិតាទូទាំងក្រសួងត្រូវរួមបញ្ចូលការពិពណ៌នាអំពីវិធីដែលសាលានឹង បង្កើត ឬ ធ្វើឲ្យមាន សមាសភាគអ្វីមួយដូចខាងក្រោមនេះ។ *[មាត្រា 1118(a)(2), ESEA.]* ដោយមិនគិតពីទម្រង់ដែលសាលាជ្រើសរើសប្រើ ត្រូវរួមបញ្ចូលសមាសភាគអ្វីមួយដូចខាងក្រោមនេះ ដើម្បីឲ្យត្រូវតាមតម្រូវការរបស់លក្ខន្តិកៈ។]

១. សាលា John H. Taggart នឹងមានសកម្មភាពដូចខាងក្រោមនេះដើម្បីឲ្យ មាតាបិតា ចូលរួមក្នុងការអភិវឌ្ឍន៍រួមគ្នា អំពីគម្រោងការចូលរួមរបស់មាតាបិតាទូទាំងសាលា ក្រោមមាត្រាលេខ១១១២ នៃច្បាប់ ESEA៖

ក្រុមប្រឹក្សាសាលាដែលសកម្ម គឺធ្វើយ៉ាងណាឲ្យគេដឹងពួពីមតិយោបល់របស់ក្រុមគ្រួសារ ហើយការបារម្ភទាំងឡាយត្រូវបានគេលើកឡើងយកមកដោះស្រាយ។ តាមរយៈ ក្រុមប្រឹក្សាសាលាថ្មីរបស់យើងនេះ មាតាបិតារបស់សាលា Taggart នឹងមានតួនាទីដ៏សំខាន់ក្នុងការបង្កើតច្បាប់សាលា និង នៅក្នុងដំណើរការនៃការសម្រេចចិត្តរបស់សាលា។

យើងផ្តល់ឱកាសឲ្យមាតាបិតាអាចជួយធ្វើការសម្រេចចិត្តទាំងអស់ ដោយបង្កើតច្បាប់នៃការធ្វើទំនាក់ទំនងដោយចំហ។ ការប្រឹងប្រែងគ្រប់បែបយ៉ាង គឺធ្វើឡើងដើម្បីផ្តល់ដំណឹងដល់មាតាបិតាអំពី កម្មវិធី អង្គប្រជុំ និង សិក្ខាសាលា ដែលរៀបចំឡើងក្នុងពេលខាងមុខ តាមរយៈ ប្រតិទិនប្រចាំខែ លិខិតផ្សព្វផ្សាយដំណឹង និង ផ្ញើសារសម្លេងតាមទូរស័ព្ទ របស់សាលាយើង។ លិខិតសម្រាប់ ការទិតៀន និង ការវាយតម្លៃ នឹងប្រើរៀងរាល់ពេលប្រជុំ ដើម្បីឲ្យមាតាបិតាអាចជួយយើងក្នុងការរៀបចំបង្កើតច្បាប់។

យើងនឹងជូនដំណឹងដល់មាតាបិតាអំពីសិទ្ធិចូលរួមរបស់ពួកគាត់ នៅក្នុងអង្គប្រជុំសម្រាប់មាតាបិតា នៅថ្ងៃទី៦ ខែតុលា ២០១៥ និង នៅពេលប្រជុំចែករបាយការណ៍ពិន្ទុរបស់យើងនៅខែ ធ្នូ កុម្ភៈ និង មេសា។

២. សាលា John H. Taggart នឹងមានសកម្មភាពដូចខាងក្រោមនេះដើម្បីឲ្យមាតាបិតាចូលរួមក្នុងវិធីពិនិត្យ និងកែលម្អ ក្រោមមាត្រាលេខ១១១៦ នៃច្បាប់ ESEA៖

ដើម្បីធ្វើយ៉ាងណាឲ្យគេទទួលមតិយោបល់ពីមាតាបិតាក្នុងវិធីកែលម្អសាលា ការរៀបចំថវិកា និង ការចំណាយប្រាក់ជំនួយ Title I នាយកសាលាពិនិត្យមើលព័ត៌មានដែលជាប់ពាក់ព័ន្ធទាំងអស់ជាមួយ ក្រុមប្រឹក្សាសាលា។ ពិភាក្សាអំពីជម្រើសដែលមាន និង ទទួលយកយោបល់ពីមាតាបិតាមុននឹងធ្វើការសម្រេចចិត្ត។

នៅនិទាឃរដូវរៀងរាល់ឆ្នាំ នឹងអាចទទួលបានព័ត៌មានអំពីថវិកា អង្គប្រជុំជាមួយក្រុមប្រឹក្សាសាលានឹងធ្វើឡើង ដើម្បីរៀបចំផែនការប្រើប្រាស់ប្រាក់ជំនួយ Title I។

៣. **<u>ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា</u>** នឹងផ្តល់ការចាត់ចែងចាំបាច់ដូចមានខាងក្រោមនេះ ជំនួយបច្ចេកទេស និងជំនួយផ្សេងៗ ដើម្បីជួយសាលាដែលទទួលជំនួយពីច្បាប់ Title I, Part A ក្នុងការគ្រោង និង ការបង្កើតសកម្មភាព សម្រាប់ការចូលរួមរបស់មាតាបិតាដែលមានប្រសិទ្ធិភាព ដើម្បីបង្កើនជោគជ័យនៃការសិក្សា និង ការសិក្សារបស់សិស្ស នៅសាលា៖

- តាមការសហការជាមួយ អ្នកត្រួតពិនិត្យផ្នែកតម្រូវការនៃប្រាក់ជំនួយ អ្នកទាក់ទងរវាងសហគមន៍ និងសាលា ក្រុមប្រឹក្សាសាលា និងមាតាបិតានៅទីក្រុងហ្វីឡាដែលហ្វ្យ៉ា (PHSC) ក្រុមប្រឹក្សាមាតាបិតាផ្នែកច្បាប់ Title I ក្រុមជំនំផ្នែកសិទ្ធិអប់រំនៅទីក្រុងហ្វីឡាដែលហ្វ្យ៉ា សិទ្ធិអំណាចរបស់មាតាបិតា (PARENT POWER) និងក្រុមមាតាបិតាផ្សេងៗទៀត ផ្តល់សិក្ខាសាលាដល់សាលា អំពីការចូលរួមរបស់មាតាបិតា។
- ផ្តល់ការហ្វឹកហ្វឺនផ្នែកការងារ <u>ដោយមាតាបិតា/អាណាព្យាបាល</u> សម្រាប់នាយកសាលា ថ្មី និង ចាស់ និង រដ្ឋបាលផ្សេងទៀត អំពីវិធីអភិវឌ្ឍដៃគូរដែលមានការសន្យា ជាមួយ មាតាបិតា/អាណាព្យាបាល។
- បង្វឹកបង្វើនបុគ្គលិក ថ្មី និង ចាស់ អំពីកាតព្វកិច្ចនៃការចូលរួមរបស់មាតាបិតា (ឧ. ការកែលម្អសាលា អ្នកទាក់ទងផ្នែកផ្តល់ជំនួយ  អ្នកទាក់ទងផ្នែកសហគមន៍សាលា អ្នកចាត់ចែងផ្នែកសហគមន៍សាលា និង អ្នកជំនួយការខាងផ្តល់ឱវាទដែលចេះពីរភាសា) ដើម្បីជួយនៅសាលា ក្នុងការបង្កើតឲ្យមានការចូលរួមពីមាតាបិតា។
- រៀបចំឲ្យមានបុគ្គលិកនៅ ការិយាល័យសមភាពផ្នែកអប់រំ ការិយាល័យផ្នែកកម្មវិធីសិក្សាពិសេស និង ការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និង សហគមន៍ សម្រាប់ជំនួយបច្ចេកទេស។
- ការិយាល័យផ្នែកធ្វើតាមតម្រូវការនៃប្រាក់ជំនួយ/Title I នឹងផ្តល់ជំនួយដល់សាលា និងអង្គការមាតាបិតា ដូចជា ក្រុមប្រឹក្សាមាតាបិតា (PAC) សម្រាប់ច្បាប់ Title I  សមាគម មាតាបិតា និងសាលា  ក្រុមជំនំផ្នែកសិទ្ធិនៃការអប់រំនៅទីក្រុងហ្វីឡាដែលហ្វ្យ៉ា សិទ្ធិអំណាចរបស់មាតាបិតា និងក្រុមដែលរៀបចំដោយមាតាបិតា ផ្សេងទៀត។
- ផ្តល់ការរៀបចំការហ្វឹកហ្វឺនផ្នែកការងារ តាមរយៈនៃ ការិយាល័យជំនួយផ្នែក ដឹកនាំ និង អភិវឌ្ឍ។
- ផ្តល់សិក្ខាសាលាដល់មាតាបិតាអំពីការគាំទ្រសិស្សឲ្យមានជោគជ័យ និងការចូលរួមពីមាតាបិតា។

៤. សាលា John H. Taggart នឹងចាត់ចែង ហើយរួមបញ្ចូលផែនការនៃការចូលរួមរបស់មាតាបិតានៅក្នុង Part A ជាមួយនឹងផែនការនៃការចូលរួមរបស់មាតាបិតា តាមកម្មវិធីផ្សេងៗ ដូចតទៅ៖ [Insert programs, such as: Head Start, Reading First, Early Reading First, Even Start, Parents As Teachers, Home Instruction Program for Preschool Youngsters, and State-operated preschool programs] ដោយ៖

យើងសម្របសម្រួលជាមួយគ្រូ Head Start (៣ នាក់) ដើម្បីបញ្ចូលអង្គប្រជុំប្រចាំខែជាមួយគ្នាសម្រាប់មាតាបិតា។ មានការបើកឲ្យដើរមើលសាលាពីរដង សម្រាប់ថ្នាក់មុនមត្តេយ្យ នៅដើមឆ្នាំសិក្សា និង នៅចុងឆ្នាំសិក្សា។ គ្រូថ្នាក់មត្តេយ្យរបស់យើង ជួប និង ធ្វើសម្ភាសន៍ ជាមួយមាតាបិតា នៅក្នុងសប្តាហ៍ទី១ ក្រោយពេលដែលថ្នាក់មត្តេយ្យចាប់ផ្តើមរៀន។

៥. សាលា John H. Taggart នឹងមានសកម្មភាពដូចតទៅ ជាមួយនឹងការចូលរួមពីមាតាបិតា ការវាយតម្លៃប្រចាំឆ្នាំ អំពីអ្វីៗដែលមាន និងប្រសិទ្ធិភាពនៃច្បាប់ចូលរួមរបស់មាតាបិតានេះ ដើម្បីបង្កើនគុណភាពនៃកម្មវិធី Title I, Part A។ ការវាយតម្លៃនឹងមានរួមបញ្ចូលទាំងការរកមើលឧបសគ្គដែលរារាំងមិនឲ្យមាតាបិតាចូលរួមបានច្រើន (ជាពិសេសចំពោះមាតាបិតាដែល ក្រខ្សត់ ពិការភាព ចេះភាសាអង់គ្លេសតិចតួច ចេះអក្សរសាស្ត្រតិចតួច ឬជាសាសន៍ ឬ ជនជាតិភាគតិច)។ សាលានឹងប្រើលទ្ធផលដែលបានពីការវាយតម្លៃអំពីការចូលរួមរបស់មាតាបិតា និងសកម្មភាពផ្សេងៗ ដើម្បីរៀបចំផែនការឲ្យកាន់តែមានប្រសិទ្ធិភាពពីការចូលរួមរបស់មាតាបិតា និងដើម្បីធ្វើការកែសម្រួលច្បាប់ចូលរួមរបស់មាតាបិតាឡើងវិញ បើសិនជាចាំបាច់ (នឹងតាមការចូលរួមពីមាតាបិតា)។

គេនឹងផ្ញើសំណួរទៅផ្ទះ សម្រាប់ឲ្យមាតាបិតា និង អាណាព្យាបាល ឆ្លើយតប។

ក្រុមប្រឹក្សាសាលា រួមជាមួយរដ្ឋបាល រួមមាន អ្នកផ្តល់ឱវាទរបស់សាលា និងអ្នកជំនួយការផ្នែកផ្តល់ឱវាទដែលចេះពីរភាសា របស់យើង នឹងលើកសំណួរទាំងនេះឡើង។

មាតាបិតានឹងចូលរួមក្នុងការលើកជាសំណួរ សម្រាប់ការចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សាសាលា និង ចូលរួមក្នុងការឆ្លើយសំណួរទាំងនេះ។

៦. សាលា John H. Taggart នឹងពង្រីកទំហំនៃការចូលរួមរបស់មាតាបិតានៅតាមសាលាឲ្យបានកាន់តែខ្លាំងឡើង ដើម្បីធ្វើយ៉ាងណាឲ្យមានប្រសិទ្ធិភាពដល់ការចូលរួមរបស់មាតាបិតា និងដើម្បីជួយដល់សម្ព័ន្ធមិត្តរវាងសាលា មាតាបិតា និងសហគមន៍ ឲ្យមានការរីកចម្រើនដល់ការសិក្សារបស់សិស្ស ទៅតាមសកម្មភាពដែលមានរៀបរាប់ជាពិសេសដូចតទៅ៖

ក. សាលា John H. Taggart ដោយមានជំនួយពីក្រសួងអប់រំ នឹងផ្តល់ជំនួយដល់មាតាបិតាតាមការសមរម្យ ក្នុងប្រធានបទដែលអាចយល់បានដូចតទៅដោយធ្វើតាមសកម្មភាពដែលបានរៀបរាប់ក្នុងប្រយោគនេះ --

- មុខវិទ្យាសិក្សាតាមខ្នាតគំរូរបស់រដ្ឋ
- ជោគជ័យលើការសិក្សារបស់សិស្សតាមខ្នាតគំរូរបស់រដ្ឋ
- ការវាយតម្លៃរបស់រដ្ឋ និងតំបន់ រួមទាំងការវាយតម្លៃតាមវិធីផ្សេងទៀត
- ការតម្រូវរបស់ច្បាប់ Title I, Part A
- វិធីតាមដានការរីកចម្រើនរបស់ក្មេង និង
- វិធីសហការជាមួយអ្នកអប់រំ

អង្គប្រជុំអំពីច្បាប់ Title I បានប្រព្រឹត្តទៅនៅថ្ងៃទី៦ ខែតុលា ២០១៥ ដើម្បីពន្យល់បង្ហាញមាតាបិតាអំពីតម្រូវការនៃច្បាប់ Title I និង ពិនិត្យមើល ខ្នាតគំរូនៃមុខវិជ្ជាសិក្សា និងខ្នាតគំរូនៃជោគជ័យក្នុងការសិក្សា។

គេនឹងចែកកូនសៀវភៅមគ្គុទេសក៍សម្រាប់ មាតាបិតា/សិស្ស ដល់មាតាបិតាទាំងអស់ដែលមកចូលរួមក្នុងកម្មវិធី យប់ជួបប្រជុំជាមួយបុគ្គលិកសាលាដំបូង។ គេនឹងជម្រាបមាតាបិតាណាដែលមិនបានមកចូលរួមថា កូនសៀវភៅនេះក៏មាននៅការិយាល័យរបស់សាលាដែរ។

អង្គប្រជុំសម្រាប់ក្រុមគ្រួសារសាលា នឹងប្រព្រឹត្តទៅជារៀងរាល់ខែ នៅថ្ងៃព្រហស្បតិ៍ក្នុងសប្តាហ៍ចុងក្រោយបង្អស់ ដើម្បីចែកចាយ ទិន្នន័យ និង ព័ត៌មាន។ ទិន្នន័យទាំងនោះរួមមាន PSSA វត្តមានអវត្តមាន និង ការគេចសាលា និង ការតាមដានការរីកចម្រើន និងជំនួយដែលមាននៅក្នុងសហគមន៍ (Eat Right Now, Mobile Dentist, Eagle Eye Van)។

ខ. សាលា John H. Taggart ដោយមានជំនួយពីក្រសួងអប់រំ នឹងផ្តល់ សម្ភារៈ និងការហ្វឹកហ្វឺន ដើម្បីជួយមាតាបិតាឲ្យធ្វើការជាមួយកូនរបស់គាត់ ដើម្បីពង្រីកជោគជ័យក្នុងការសិក្សា ដូចជាការហ្វឹកហ្វឺនផ្នែកអក្សរសាស្ត្រ និងការប្រើបច្ចេកវិទ្យា ឲ្យបានសមរម្យដើម្បីឲ្យមាតាបិតាចូលរួមដោយ៖

នឹងមានបន្ទប់ផ្តល់ជំនួយដល់មាតាបិតានៅសាលា Taggart។ មាតាបិតាដែលស្ម័គ្រចិត្ត ឬ បុគ្គលិកសាលា Taggart នឹងធ្វើការនៅបន្ទប់ផ្តល់ព័ត៌មាននេះ។ អ្នកស្ម័គ្រចិត្តនឹងជួយលើកទូរស័ព្ទ និងបន្តទូរស័ព្ទ ចែកចាយព័ត៌មានរបស់សាលាជូនដល់មាតាបិតាដែលមកកាន់សាលា និងជួយអភិវឌ្ឍការចូលរួមរបស់សហគមន៍បន្ថែមទៀត។

នឹងមានរៀបចំកម្មវិធីផ្សេងៗ ពីដើមឆ្នាំ ដល់ចុងឆ្នាំសិក្សា ដើម្បីពន្យល់ និង ហ្វឹកហ្វឺន មាតាបិតាអំពីបញ្ហានៃការសិក្សា ដូចជាការត្រៀមខ្លួនសម្រាប់ការប្រឡង PSSA។

គេបានបង្ហាញជូនមាតាបិតានូវឯកសារដែលទាក់ទងនឹង ខ្នាតគំរូសិក្សាសំខាន់ៗរបស់រដ្ឋ (Common Core State Standards) នៅពេលមានសិក្ខាសាលា។ ឯកសារទាំងនេះជួយឲ្យមាតាបិតាដឹងអំពីអ្វីៗដែលកូនសិក្សានៅសាលា។ គេក៏ផ្តល់ឲ្យមាតាបិតានូវសៀវភៅជាច្រើន នៅពេលមានសិក្ខាសាលាអំពីអក្សរសិល្ប៍ខុសៗគ្នា។ យោងទៅលើលទ្ធផលនៃការប្រឡង PSSA នឹងមានសិក្ខាសាលាបន្ថែមទៀតអំពីអក្សរសិល្ប៍ និង សិក្ខាសាលារបស់អ្នកជំនួយការផ្នែកផ្តល់ឱវាទដែលចេះពីភាសា សម្រាប់មាតាបិតាដែលនិយាយពីភាសារបស់យើង។

គ. សាលា John H. Taggart ដោយមានជំនួយពីក្រសួងអប់រំ នឹងអប់រំគ្រូ បុគ្គលិកដែលបម្រើសិស្ស នាយកសាលា និងបុគ្គលិកផ្សេងៗទៀត អំពីវិធីស្រាវជ្រាវរកការប្រាស្រ័យទាក់ទង និងសហការជាមួយ មាតាបិតាជាដៃគូដែលមានសិទ្ធិស្មើភាពគ្នា តាមការឲ្យតម្លៃ និងការប្រើ ការបរិច្ចាគរបស់មាតាបិតា អំពីវិធីអនុវត្ត និងចាត់ចែងកម្មវិធីសម្រាប់មាតាបិតា ព្រមទាំងបណ្តុះចំណងរវាង មាតាបិតា និង សាលា ដោយ៖

អង្គប្រជុំអំពី ការឆ្លើយតបទៅនឹង ការធ្វើអន្តរាគមន៍ និង ការបង្ហាត់បង្រៀន (Response To Interventions and Instructional) ប្រចាំសប្តាហ៍ នឹងពាក់ព័ន្ធជាមួយ រដ្ឋបាល បុគ្គលិកជំនួយ បុគ្គលិកដែលមកពីអង្គការខាងក្រៅ និង មាតាបិតា។ គេនឹងប្រើពិធីសាស្រ្តដើម្បីពិនិត្យមើលកិច្ចការរបស់សិស្ស ហើយសមាជិកបុគ្គលិកនឹងរួមបញ្ចូល វិធីសាស្រ្ត និង បច្ចេកទេស ដែលនឹងរួមបញ្ចូលការអប់រំកូននៅក្នុងនោះផងដែរ។ នៅពេលប្រជុំគ្រូទៅតាមកម្រិតថ្នាក់ និងការហ្វឹកហ្វឺនផ្នែកការងាររបស់គ្រូ គេនឹងផ្តល់ព័ត៌មានជូនគ្រូ ដែលពួកគាត់អាចជម្រាបដល់មាតាបិតានៅពេលប្រជុំចែករបាយការណ៍ពិន្ទុ និង វិធីសាស្រ្ត អំពីវិធីដែលអាចទាក់ទងជាមួយមាតាបិតាឲ្យបានកាន់តែប្រសើរឡើង។ បុគ្គលិកផ្តល់ជំនួយនៅក្នុងសាលា ដូចជា អ្នកផ្តល់ឱវាទ និងអ្នកជំនួយការផ្នែកផ្តល់ឱវាទដែលចេះពីភាសា អាចផ្តល់ជំនួយដល់គ្រូក្នុងការទាក់ទងដ៏មានប្រសិទ្ធិភាពជាមួយមាតាបិតា។

**ឃ**. សាលា John H. Taggart តាមតែអាចធ្វើទៅបាន និងតាមការសមរម្យ នឹងរៀបចំ នឹងបញ្ចូលកម្មវិធីចូលរួមរបស់មាតាបិតា និងសកម្មភាពផ្សេងៗ ជា មួយកម្មវិធី Head Start, Reading First, Early Reading First, Even Start, កម្មវិធីបង្ហាត់បង្រៀននៅផ្ទះ សម្រាប់កុមារមុនថ្នាក់មត្តេយ្យ កម្មវិធីមាតាបិតាជាគ្រូ និងថ្នាក់មុនមត្តេយ្យរបស់រដ្ឋ និងកម្មវិធីផ្សេងៗទៀត ព្រមទាំងធ្វើឲ្យមានសកម្មភាពផ្សេងៗទៀត ដូចជា មណ្ឌលផ្តល់ព័ត៌មានសម្រាប់មាតាបិតា ដែលនឹងជួយលើកទឹកចិត្ត ហើយជួយដល់មាតាបិតាឲ្យមានការចូលរួមឲ្យបានពេញលេញក្នុងការអប់រំកូន ដោយៈ

ចាប់ផ្តើមនៅខែមករា គ្រូរបស់យើងសហការជាមួយគ្រូថ្នាក់មត្តេយ្យ ដើម្បីរៀបចំសកម្មភាពរួមគ្នា ការមកមើលថ្នាក់រៀន និង ការជួបប្រជុំជាមួយមាតាបិតា ដើម្បីត្រៀមសម្រាប់ការផ្លាស់ប្តូរនាពេលខាងមុខ។ មានអង្គប្រជុំប្រចាំខែជាមួយមាតាបិតានៃសិស្សថ្នាក់មុនមត្តេយ្យរបស់យើង។ មានការបើកឲ្យដើរមើលសាលាពីរដង សម្រាប់ថ្នាក់មុនមត្តេយ្យ នៅដើមឆ្នាំសិក្សា និង នៅចុងឆ្នាំសិក្សា។

យើងខ្ញុំនឹងចំណាយប្រាក់ក្នុងការទិញសៀវភៅសម្រាប់មាតាបិតា និង សៀវភៅរឿងសម្រាប់មាតាបិតាអានឲ្យកូនស្តាប់ ដែលមាននៅក្នុងបណ្ណាល័យសម្រាប់ឲ្យមាតាបិតាខ្ចី។

**ង**. សាលា John H. Taggart នឹងមានសកម្មភាព**ដូចមាន**ខាងក្រោម**នេះ** ដើម្បីធ្វើយ៉ាងណាឲ្យព័ត៌មានដែលទាក់ទងនឹង សាលា និង មាតាបិតា - **កម្មវិធី** អង្គប្រជុំ និងសកម្មភាពផ្សេងៗ **ត្រូវផ្ញើទៅមាតាបិតារបស់ក្មេងដែលចូលរួម** តាមការងាយស្រួលយល់ និងជាឯកសណ្ឋាន ដោយមានរួមទាំង **ទម្រង់ផ្សេងទៀត** តាមសេចក្តីស្នើ និង តាមលទ្ធភាពដែលអាចធ្វើទៅបាន **ជា**ភាសាដែលមាតាបិតាអាចយល់បានៈ

សម្រាប់ថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី៣ សាលាផ្ញើក្របដាក់ឯកសារទៅផ្ទះរៀងរាល់ថ្ងៃពុធ ដែលមានព័ត៌មានដែលជាប់ពាក់ព័ន្ធ និង ទាន់សភាពការណ៍។ ឯកសារទាំងអស់ដែលបានរៀបចំឡើងគឺបានគិតដល់មាតាបិតា និងផ្ញើទៅផ្ទះតាមទម្រង់ និង ជាភាសាដែលអាចយល់បាន។

មាតាបិតាទទួល ព្រឹត្តិបត្រ/ប្រតិទិន ប្រចាំខែ។ នាយកសាលានឹងផ្ញើ លិខិតជូនដំណឹង និង លិខិតផ្សព្វផ្សាយដំណឹងពិសេសៗ ទៅផ្ទះ ទៅតាមសភាពការណ៍ជាក់ស្តែង។ អ្នកជំនួយការផ្នែកផ្តល់ឱវាទដែលចេះពីរភាសា អាចជួយបកប្រែព័ត៌មាននៅក្នុងសាលា។ ក្រសួងអប់រំក៏ផ្តល់ការបកប្រែភាសា តាមរយៈការស្នើសុំផងដែរ។

មាតាបិតានឹងចូលរួមក្នុងអង្គប្រជុំ ក្រុមប្រឹក្សាសាលា ដែលប្រព្រឹត្តិទៅរៀងរាល់ថ្ងៃព្រហស្បតិ៍នៃសប្តាហ៍ចុងខែ។ នៅក្នុងអង្គប្រជុំទាំងនេះ បុគ្គលិក បុគ្គលិកសាលា សហគមន៍ ពាណិជ្ជករ និង ដៃគូពីសាកលវិទ្យាល័យ បានណាត់ពេលដើម្បីមកពន្យល់បង្ហាញ។ តាមលក្ខណៈនេះ គេបានជម្រាបជូនមាតាបិតាពីជំនួយសំខាន់ៗដែលមាននៅក្នុងសហគមន៍។

## ផ្នែកទី III សមាសភាគនៃច្បាប់សម្រាប់ការចូលរួមរបស់មាតាបិតាទូទាំងសាលា

កំណត់សំគាល់៖ ច្បាប់នៃការចូលរួមសម្រាប់មាតាបិតារបស់សាលា អាចរួមបញ្ចូលវគ្គ និងរៀបរាប់ពីសកម្មភាពតាមការជ្រើសរើសផ្សេងទៀត ដែលសាលាតាមការពិគ្រោះជាមួយមាតាបិតា ជ្រើសរើសធ្វើដើម្បីបង្កើនចំនួនមាតាបិតា សម្រាប់ការចូលរួមនៅសាលា និង ប្រព័ន្ធសាលា ដើម្បីជួយក្មេងឲ្យមានជោគជ័យក្នុងការសិក្សា ដូចជា សកម្មភាពតាមការជ្រើសរើសដែលបានចុះក្រោម មាត្រា១១១៨(e) នៃច្បាប់ ESEA៖

- នាំឲ្យ មាតាបិតា ចូលរួមក្នុងការអភិវឌ្ឍន៍ការហ្វឹកហ្វឺន គ្រូ នាយកសាលា និង បញ្ញវន្តផ្សេងៗទៀត ដើម្បីបង្កើនប្រសិទ្ធិភាពនៃការហ្វឹកហ្វឺន
- ផ្តល់ការហ្វឹកហ្វឺនផ្នែកអក្សរសាស្រ្តតាមការចាំបាច់ដល់មាតាបិតា ពីថវិកា Title I, Part A បើសិនជាក្រសួងអប់រំអស់ថវិការសម្រាប់ការហ្វឹកហ្វឺននោះ
- បង់ថ្លៃចំណាយ តាមការសមរម្យ និងចាំបាច់ ដែលទាក់ទងនឹងសកម្មភាពនៃការចូលរួមរបស់មាតាបិតា រួមទាំងការដឹកជញ្ជូន ដើម្បីឲ្យមាតាបិតាមានលទ្ធភាពចូលរួមក្នុងអង្គប្រជុំដែលទាក់ទងនឹងសាលា និង ការហ្វឹកហ្វឺនផ្សេងៗ
- ហ្វឹកហ្វឺនមាតាបិតា ដើម្បីបង្កើនការចូលរួមពីមាតាបិតា ផ្សេងទៀត
- រៀបចំអង្គប្រជុំនៅសាលាតាមពេលវេលាខុសៗគ្នា ឬមានអង្គប្រជុំនៅក្នុងផ្ទះ រវាង គ្រូ ឬ បញ្ញវន្តផ្សេងៗ ដែលមានការចូលរួមផ្ទាល់ជាមួយក្មេងដែលចូលរួម ជាមួយមាតាបិតាដែលមិនអាចចូលរួមប្រជុំនៅសាលាបាន ម្បីបង្កើនការចូលរួមឲ្យកាន់តែច្រើនពីមាតាបិតាក្នុងការអប់រំរបស់កូន។
- ការអនុម័ត និង ការអនុវត្តន៍ តាមគំរូណាដែលនឹងជួយបង្កើននូវការចូលរួមរបស់មាតាបិតា។
- បង្កើតក្រុមប្រឹក្សាមាតាបិតាទូទាំងក្រសួង ដើម្បីផ្តល់យោបល់ទៅលើរឿងរ៉ាវគ្រប់យ៉ាង ដែលទាក់ទងនឹងការចូលរួមរបស់មាតាបិតា ក្នុងកម្មវិធីរបស់ច្បាប់ Title I, Part A។
- បង្កើតឲ្យមានតួនាទីត្រឹមត្រូវ សម្រាប់អង្គការនៅក្នុងសហគមន៍ និងពាណិជ្ជកម្មផ្សេងៗ រួមទាំង អង្គការសាសនា ក្នុងសកម្មភាពនៃការចូលរួមរបស់មាតាបិតា និង
- ផ្តល់ជំនួយដែលសមហេតុសមផលផ្សេងៗ សម្រាប់សកម្មភាពនៃការចូលរួមរបស់មាតាបិតា តាមមាត្រាលេខ ១១១៨ តាមការស្នើសុំរបស់មាតាបិតា។

* * * * *

## ផ្នែកទី IV ការអនុម័ត

ច្បាប់នៃការចូលរួមរបស់មាតាបិតា នៃ សាលា John H. Taggart នេះ បានអភិវឌ្ឍរួមគ្នាជាមួយ និងមានការយល់ព្រមពីមាតាបិតា ដោយបានសំអាងដោយអង្គប្រជុំមាតាបិតា ដែលមានចុះហត្ថលេខាចូលរួម នៅថ្ងៃទី៦ ខែតុលា ២០១៥។

សាលានឹងចែកជូនច្បាប់នេះទៅមាតាបិតាទាំងអស់ ឲ្យបានមុនថ្ងៃ ឬនៅថ្ងៃ **ទី៣០ ខែកញ្ញា ឆ្នាំ២០១៥**។

______________________________

*(Signature of Principal)*

______________________________

(Date)